# របាយការណ៍ការិយាល័យសវនកម្មរបស់សាសនាចក្រ ឆ្នាំ 2010

បង្ហាញដោយ រ៉ូបឺត ដបុលយូ ខានវ៉េល
នាយកគ្រប់គ្រង ការិយាល័យសវនកម្មសាសនាចក្រ

ជូនចំពោះគណៈប្រធានទីមួយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

បងប្អូនប្រុសជាទីស្រឡាញ់ ៖

ដូចដែលបានសរសេរក្នុងវិវរណៈ កណ្ឌទី 120 នៃគោលលទ្ធិ និង សេចក្តីសញ្ញា ក្រុមប្រឹក្សាបែងចែកដង្វាយមួយភាគក្នុងដប់ អនុញ្ញាតក្នុងការចំណាយមូលនិធិរបស់សាសនាចក្រ ។ ក្រុមប្រឹក្សានេះ ត្រូវបានរៀបចំឡើងដោយគណៈប្រធានទីមួយ កូរ៉ុមពួកសាវកដប់ពីរនាក់ និង គណៈប៊ីស្សពជាអធិបតី ។

ក្រុមប្រឹក្សានេះ អនុមតិថវិកាសម្រាប់ការិយាល័យ និងប្រតិបត្តិការ និងប្រាក់បុរេប្រទានដែលទាក់ទងនឹងអង្គភាពសាសនា ។ បន្ទាប់ពីទទួលបានការអនុមតិរបស់ក្រុមប្រឹក្សា ការិយាល័យសាសនាចក្រត្រូវចាយមូលនិធិទាំងឡាយ តាមថវិកាដែលបានអនុមតិយ៉ាងខ្ជាប់ខ្ជួន ហើយឲ្យស្របទៅតាមគោលការណ៍ និងទម្រង់ការនៃសាសនាចក្រ ។ ការិយាល័យសវនកម្មសាសនាចក្រ ត្រូវបានអនុញ្ញាតឲ្យចូលទៅគ្រប់កំណត់ហេតុ និងប្រព័ន្ធចាំបាច់ទាំងអស់ ដើម្បីវាយតម្លៃសមត្ថភាពគ្រប់គ្រងវិក្កយបត្រមូលនិធិ ការចំណាយ និងការការពារធនធានសាសនាចក្រ ។ ការិយាល័យសវនកម្មសាសនាចក្រ គឺជាការិយាល័យឯករាជ្យពីការិយាល័យ និងប្រតិបត្តិការផ្សេងទៀតទាំងអស់ ព្រមទាំងបុគ្គលិកដែលបានបញ្ជាក់ជាគណនេយ្យករសាធារណៈ ជាសវនករផ្ទៃក្នុងអង្គភាពដែលមានការបញ្ជាក់ ជាសវនករលើប្រព័ន្ធព័ត៌មាន ដែលមានការបញ្ជាក់ និងអ្នកជំនាញការទទួលបានសារតាំងដទៃទៀត ។

ផ្អែកទៅលើសវនកម្មដែលបានធ្វើរួចហើយ ការិយាល័យសវនកម្មសាសនាចក្រ មានទស្សនៈថា រាល់ឯកសារទាំងអស់ ត្រូវបានបង្គ្រប់ បានទទួលការចែកចាយ និងបានធ្វើការចំណាយ ហើយធនធានសាសនាចក្រ សម្រាប់ឆ្នាំ 2010 ត្រូវបានកត់ត្រាទុក និងគ្រប់គ្រងតាមការអនុវត្តគណនេយ្យត្រឹមត្រូវ ថវិកាទាំងឡាយមានការអនុមតិ ហើយស្របតាមគោលការណ៍ និងទម្រង់ការរបស់សាសនាចក្រ ។
សូមដាក់ជូនដោយការគោរពដ៏ជ្រាលជ្រៅ

ការិយាល័យផ្នែកសវនកម្មសាសនាចក្រ
រ៉ូប៊ឺត ដបុលយូ ខានវ៉េល
នាយកគ្រប់គ្រង